# វីរុសកូរ៉ូណា ថ្មី

### អ្វីដែលលោកអ្នកចាំបាច់ត្រូវយល់ដឹង

LONGBEACH HEALTH & HUMAN SERVICES

WWW.LONGBEACH.GOV/COVID19

## តើវីរុសកូរ៉ូណាថ្មី ជាអ្វីទៅ ?

វីរុសកូរ៉ូណាថ្មី (2019-nCoV) គឺជាវីរុសផ្លូវដង្ហើម ដែលត្រូវបានកំណត់រកឃើញជាដំបូង នៅខែធ្នូ ឆ្នាំ 2019 ក្នុងទីក្រុងវូហាន ខេត្តហ៊ូប៉ី ប្រទេសចិន ។ វីរុសនេះអាចមានប្រភពដើមចេញពីសត្វ ប៉ុន្តែ នាពេលឥឡូវនេះ វាកំពុងឆ្លងពីមនុស្សទៅមនុស្ស ។

ទោះបីជាហានិភ័យ របស់ 2019-nCoV មានកម្រិតទាបក្តី ក៏នាយកដ្ឋានសុខាភិបាលឡុងប៊ិច កំពុងធ្វើការតាមដានត្រួតពិនិត្យ ដាក់យកចិត្តទុកដាក់ លើសភាពការណ៍ ហើយ ចាត់វិធានការនានាដើម្បីរក្សាឱ្យឡុងប៊ិចមានសុវត្ថិភាព ។

## តើមានរោគសញ្ញា អ្វីខ្លះ ?

រោគសញ្ញា ដែលមានរាយការណ៍ នាពេលបច្ចុប្បន្ននេះ រួមមាន ជំងឺផ្លូវដង្ហើមពីកម្រិតស្រាល ដល់កម្រិតធ្ងន់ធ្ងរ ដោយមាន គ្រុនក្តៅ ក្អក និង ពិបាកដកដង្ហើម ។

- គ្រុនក្តៅ
- ដកដង្ហើម ខ្លីៗ
- ក្អក

## តើវាឆ្លងតាមរបៀបណាខ្លះ ?

- ទំនាក់ទំនងជិតស្និទ លក្ខណៈបុគ្គល ដូចជាការប៉ះកាន់ និងការចាប់ដៃ
- តំណក់ទឹកមាត់ ពេលក្អក និងកណ្តាស់
- ការប៉ះ ភ្នែក ច្រមុះ និង មាត់ របស់លោកអ្នក ដោយដៃមិនបានលាងសម្អាត

## តើខ្ញុំប្រឈមនឹងហានិភ័យ ដែរឬទេ ?

ខ្ញុំបានធ្វើដំណើរ ក្នុងរយៈពេល ពីរសប្តាហ៍ចុងក្រោយនេះ ។

ឬ

ខ្ញុំបាននៅជិត អ្នកដែលមានផ្ទុកវីរុស 2019-nCoV ។

\+

ខ្ញុំធ្លាក់ខ្លួនឈឺ ដោយមាន គ្រុនក្តៅ និង ក្អក ឬ ដកដង្ហើមខ្លីៗ ។

=

**សូមទំនាក់ទំនង ទៅអ្នកផ្តល់សេវាថែទាំសុខភាព របស់លោកអ្នក ដើម្បីកំណត់ថាតើត្រូវធ្វើតេស្ត ឬអត់នោះ ។**

## តើមានការកំណត់រករោគសញ្ញា ដោយរបៀបណាដែរ ?

អ្នកផ្តល់សេវាថែទាំសុខភាព នឹងវាយតម្លៃ អ្នកជំងឺ ហើយ ធ្វើការពិគ្រោះជាមួយ នាយកដ្ឋានសុខាភិបាល ថាតើត្រូវធ្វើតេស្ត ឬអត់នោះ ។

## តើមានការព្យាបាល បែបណាខ្លះ ?

មនុស្សភាគច្រើន នឹងជាសះស្បើយ ដោយខ្លួនឯង ។ គ្មានការព្យាបាល ជាក់លាក់សម្រាប់ ការឆ្លងវីរុសកូរ៉ូណា ថ្មី នេះនោះទេ ។

## តើខ្ញុំបង្ការការរីករាលដាលវីរុសកូរ៉ូណា ថ្មី ឆ្នាំ 2019 បាន ដោយរបៀបណាដែរ ?

- សូមលាងសម្អាតដៃរបស់លោកអ្នក ដោយសាប៊ូ និងទឹក ក្នុងរយៈពេលយ៉ាងហោចណាស់ 20 វិនាទី ឱ្យបានញឹកញាប់ ។
- សូមកុំប៉ះ ភ្នែក ច្រមុះ និងមាត់ របស់លោកអ្នក ដោយដៃ ដែលមិនបានលាងសម្អាត ឱ្យសោះ ។
- សូមជៀសវាងកុំនៅជិត អ្នកមានជំងឺ ។
- គ្រប មាត់ ឬច្រមុះ របស់លោកអ្នក ដោយក្រដាស់ជូតមាត់ ពេលក្អក ឬកណ្តាស់ ហើយ បោះចោលក្រដាស់ជូតមាត់នោះ ទៅក្នុងធុងសម្រាម ។
- សូមនៅក្នុងផ្ទះ ប្រសិនបើលោកអ្នកឈឺ ។
- សូមសម្អាត និង កម្ចាត់មេរោគ ឱ្យបានញឹកញាប់ ចំពោះវត្ថុ និងផ្ទៃរាបដែលមានការប៉ះកាន់នោះ ។